ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សភាផ្នែករដ្ឋប្បវេណី *******

---

សំណុំរឿងរដ្ឋប្បវេណី

លេខ ៩៥

ចុះថ្ងៃទី២៣ខែកុម្ភៈឆ្នាំ២០០០

សាលដីកា

លេខ : ១៤២

ចុះថ្ងៃទី២៧ខែកក្កដាឆ្នាំ២០០០

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ :

១_ ឯកឧត្តម ខិន មុន្នី ប្រធាន

២_ លោក ប៉ែន ស៊ុន ចៅក្រម

៣_ លោក ស៊ិន ខឹម ចៅក្រម

៤_ លោក យស់ សូខឿន ចៅក្រម

៥_ លោក គង់ ភិរុណ ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក ទឹម សម្ផស្សរិទ្ធិ

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៧៨៦ចុះថ្ងៃទី០៨ ខែវិច្ឆិកាឆ្នាំ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥៥៦ ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ គឹម ធូ ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិ ខ្មែរ មុខរបរជាងទង ទីលំនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះគឹម អុន ( រ ) ម្តាយឈ្មោះ ហ៊ួ ស៊ុត ( រ ) ប្រពន្ធឈ្មោះ ស៊ឹម ស្រស់ មានកូន០២ នាក់ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ស៊ឹម ស្រស់ ភេទស្រី អាយុ ៣៣ឆ្នាំ ជាតិ ខ្មែរ មុខរបរ ស៊ីឈ្នួលកាត់ដេរ មានទីលំនៅផ្ទះលេខ៩៣ ផ្លូវលេខ១៧២ សង្កាត់ផ្សារកណ្តាល ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ ហង្ស ស៊ឹម ( ស ) ម្តាយឈ្មោះ យី យ៉ាន ( ស ) ប្តីឈ្មោះ គឹម ធូ មានកូន ០២ នាក់ ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តី

បានឃើញបណ្តឹងសាទុក្ខលេខ ៥៥ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ឈ្មោះ គីម វណ្ណៈ ជាអ្នកទទួលសិទ្ធិពី គីម ធុ បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ៧៩៦ ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៩៥ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៨_០១_៩៩ របស់ឈ្មោះស៊ុម ស្រស់ បានប្តឹងសុំផ្តាច់សមគ្គ-សង្វាស ពីឈ្មោះ គីម ធុ ដោយសំអាងហេតុថា ខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះនេះ តាំងពីឆ្នាំ ១៩៨៩ រហូតដល់ឆ្នាំ១៩៩៥ ខ្ញុំមានផ្ទៃពោះកូនទី២ បាន៨ខែកន្លះ ស្រាប់តែប្តីខ្ញុំចុះចោលផ្ទះរហូតដល់សព្វថ្ងៃ គាត់មានប្រពន្ធមួយទៀត ជាហេតុធ្វើឱ្យខ្ញុំអស់មនោសញ្ចេតនាជាមួយឈ្មោះ គីម ធុ នេះតទៅ ។

តាមចម្លើយឈ្មោះស៊ុម ស្រស់ បានឆ្លើយបញ្ជាក់ថា ខ្ញុំបានរៀបការជាមួយឈ្មោះគីម ធុ កាលពីថ្ងៃទី ២២_៤_១៩៨៩ ។ ក្នុងពេលរៀបការ និងរួមរស់ជាមួយគ្នា ក្នុងនាមប្តីប្រពន្ធរហូតដល់ឆ្នាំ១៩៩៥ ខ្ញុំក៏មានទំងន់កូនទី២ បាន ៨ខែកន្លះ ប្តីខ្ញុំបានចុះចោលផ្ទះទៅមានប្រពន្ធមួយទៀត រហូតដល់សព្វថ្ងៃ ។ សព្វថ្ងៃខ្ញុំមានកូន ០២នាក់ ១_ ឈ្មោះ ស៊ុម សេរីវត្ថ ភេទស្រី អាយុ៧ឆ្នាំ , ២_ឈ្មោះ ស៊ុម វាសនា ភេទប្រុស អាយុ៥ឆ្នាំ ហើយមានទ្រព្យសម្បត្តិរួមៈ ដីទំហំ១៣ ,៥ម×៦ ,៥ម ស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យ មានព្រំប្រទល់ខាងជើងទល់ផ្លូវលំ , ខាងលិចទល់ព្រំដី ម៉ែន តន្ថា ខាងត្បូងទល់ព្រំដី ណិប យឿន និងខាងកើតទល់ព្រំដី លី យ៉ុង ។

ដីនេះ ខ្ញុំទិញ ៦តម្លឹង ៥ជី គឺខ្ញុំខ្ចីលុយម្តាយ ២តម្លឹងផង ។

សព្វថ្ងៃនេះ ខ្ញុំនៅជំពាក់បំណុលគេ ៣.០០០$ ( បីពាន់ដុល្លា ) ដោយខ្ញុំខ្ចីគេ ចំណាយក្នុងការឆ្លងទន្លេ និង ព្យាបាលកូនត្រូវគ្រាក់ទឹក ។

ដីនេះមានតម្លៃ ៣.០០០$ និង សំណូមពរ សុំសិទ្ធិគ្រប់គ្រងកូនទាំង ០២នាក់ និង ដីទំហំ ១៣ ,៥ម×៦ ,៥ម ចំពោះអាហារកិច្ចខ្ញុំមិនប្តឹងទាមទារទេ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២៦ " ច " ចុះថ្ងៃទី១០ ខែ មិថុនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្តឹង ចុះថ្ងៃទី ២៨_០១_១៩៩៩ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_ ឱ្យនារីឈ្មោះ ស៊ុម ស្រស់ និង ឈ្មោះ គីម ធុ ផ្តាច់សមគ្គសង្វាសពីគ្នា ចាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះ តទៅ តាមការព្រមព្រៀងរបស់គូភាគី ដោយដាក់កំហុសទៅលើឈ្មោះ គីម ធុ។

៣_ ឱ្យនារីឈ្មោះ ស៊ុម ស្រស់ ស្ថិតក្នុងភាពមេម៉ាយចំនួន៣០០ថ្ងៃ ចាប់តាំងពីថ្ងៃនេះតទៅ ។

៤_ ប្រគល់កូនទាំងពីរនាក់ឈ្មោះ ស៊ុម សេរីវត្ថ ភេទស្រី អាយុ៧ឆ្នាំ ឈ្មោះ ស៊ុម វាសនា

ភេទប្រុស អាយុ ៥ឆ្នាំ ឱ្យទៅឈ្មោះ ស៊ីម ស្រស់ គ្រប់គ្រងចិញ្ចឹមបីបាច់ ចាប់តាំងពីថ្ងៃនេះតទៅ ។

មាតាបិតាដែលលែងលះគ្នា ត្រូវបំពេញសិទ្ធិ និង ករណីកិច្ចអប់រំ ថែទាំចិញ្ចឹមកូន តាម មាត្រា ៧៤ ,៧៥ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥_ ដីទំហំ ១៣ ,៥៣×៦ ,៥៣ ដែលមានបង្កាន់ដៃលេខ២១០៦០ ចុះថ្ងៃទី០២_៦_១៩៩៤ ស្ថិតនៅភូមិថ្មី សង្កាត់ស្ទឹងមានជ័យត្រូវប្រគល់ឱ្យឈ្មោះ ស៊ីម ស្រស់ សំរាប់បែងចែកសងបំណុលគេ និង ដោះស្រាយចិញ្ចឹមកូនទាំង ២ ចាប់ពីថ្ងៃនេះតទៅ ។

៦_ បង្គាប់ឱ្យឈ្មោះ ស៊ីម ស្រស់ បង់ប្រាក់ប្រដាប់ក្តី ៧០០០រៀល តាមការស្ម័គ្រចិត្តគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល និង រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល ។

៧_ សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូភាគីសំរេចបើកផ្លូវប្តឹង ឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២០ " ច " ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៩៩៩ របស់លោក គីម ធូ បានប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ២៦ " ច " ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៩៦ ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់ឈ្មោះ គីម ធូ ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយទាស់ និងគតិច្បាប់ ។

២_ តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២៦ " ច " ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការទាំងមូល ។

៣_ កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ គឺពន្ធចុះបញ្ជីក្តី និងពន្ធថ្លឹងចំនួន២៥៥០រ,០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០រ,០០ ចំណាយលើការប្រគល់ដីកាកោះចំនួន ៥០០០រ,០០ និង លើអាជ្ញាធរតុលាការចំនួន ៥០០០រ,០០ សរុប ១៣.០០០រ,០០ ។

៤_ សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៥៥ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ឈ្មោះ គីម វណ្ណៈ ជាអ្នកទទួលសិទ្ធិពី គីម ធូ បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៧៩៦ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសាលដីកាទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ២២_០៣_២០០០ របស់ឈ្មោះ គីម ធូ

បានឃើញ សារណាតប ចុះថ្ងៃទី ០៦_៤_២០០០ របស់ឈ្មោះ ស៊ឹម ស្រស់

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ថា: សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ចុះ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ឈ្មោះ គឹម ផូ ជាចុងចម្លើយនិងជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : សាលាឧទ្ធរណ៍កាត់សេចក្តីពុំត្រឹមត្រូវ កន្លងមកខ្លួនធ្លាប់បានឱ្យលុយ កាត់ដល់កូនខ្លះៗដែរ តាមរយៈនាយកសាលា សូមសំណូមពរសុំសិទ្ធិគ្រប់គ្រងកូនទាំងពីរ និង សុំបែងចែកដី ជាពីរចំណែកស្មើគ្នា ព្រោះដីនេះ ជាទ្រព្យសម្បត្តិរួម ។

ក្រោយពីបានស្តាប់ចម្លើយរបស់ឈ្មោះ ស៊ឹម ស្រស់ ជាដើមចោទនិងជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : ខ្លួនមិនអាចឱ្យតាមសំណូមពរ លោក គឹម ផូ បានទេ ព្រោះ ដីនេះ ខ្លួនយកលុយពីម្តាយខ្លួនមកទិញ ហើយឈ្មោះ គឹ ផូ ជាប្តីបានចុះចោលខ្លួនទៅមានប្រពន្ធថ្មី ជាង៥ឆ្នាំ ហើយៗ នៅពេលកូនខ្លួនមានជំងឺត្រូវគ្រាក់ទឹកបុកនោះ គេពុំដែលមកសួរនាំ ឬ ជួយព្យាបាលកូនបន្តិចណាសោះ ឡើយ ខ្លួនបានខ្ចីលុយគេយកមកព្យាបាលកូនអស់ប្រហែល ៣០០០ដុល្លាអាមេរិក ទាំងការទាំងដើម ។

សំណូមពរ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូក្តី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥៤៥ ចុះថ្ងៃទី ១៣_១២_៩៩ របស់លោក គឹម ផូ ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងរដ្ឋប្បវេណីនេះ មកជំនុំជំរះបានតាម មាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា លោក គឹម ផូ បានចុះចោលប្រពន្ធ និង កូនទាំងពីរនាក់ តាំង ពីឆ្នាំ ១៩៩៥ រហូតដល់ឆ្នាំ ១៩៩៨ បានទៅរៀបការប្រពន្ធថ្មីមួយទៀត ហើយពុំបានជួយឧបត្ថម្ភ និង ព្យាបាលកូនមានរបួស ដោយសារគ្រាក់ទឹកបុកឱ្យរបួសនោះឡើយ ។

- យល់ឃើញថា ការប្រគល់ដីជាសម្បត្តិរួមទៅឱ្យដើមចោទគ្រប់គ្រង ដើម្បីសងបំណុល គេ និង ចិញ្ចឹមកូននោះ ជាការត្រឹមត្រូវទៅតាមមាត្រា៧០ វាក្យខ័ណ្ឌទី៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

- យល់ឃើញថា សាលដីកាឧទ្ធរណ៍លេខ ៧៩៦ ចុះថ្ងៃទី ០៨-១១-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី

១- ទទួលបណ្តឹងសាទុក្ខលេខ ៩៤៥ ចុះថ្ងៃទី ១៣-១២-៩៩ របស់លោក គឹម ធូ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីកាឧទ្ធរណ៍លេខ ៧៩៦ ចុះថ្ងៃទី ០៨-១១-៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទំាងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ដែលលោក គឹម ធូ បានបង់ទុកនៅតុលាការកំពូល ចំនួន ១៩.០០០រៀល គឺ ៖

- ពន្ធចុះបញ្ជីក្តី និង ពន្ធឃ្លឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយក្នុងការប្រគល់ដីកាកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០០។